

# កម្មវិធីអភិបាលកិច្ចទឹកតំបន់មេគង្គ នៃអង្គការអុកស្វាម
# គម្រោងបរិយាបន្នទឹក ដំណាក់កាលទី២

## ការវាយតម្លៃបញ្ចប់គម្រោង
## របាយការណ៍បញ្ចប់គម្រោង ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤

រៀបរៀងដោយ Mark Deasey (ប្រធានក្រុម), Vo Thi Tam និង Bounthavivanh Mixap

This project is supported by:

Australian Aid

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

Embassy of Switzerland

OXFAM

# ១. មូលន័យសង្ខេប

**សាវតារ៖** កម្មវិធីអភិបាលកិច្ចទឹកតំបន់មេគង្គប្រកបដោយបរិយាបន្ន ដំណាក់កាលទី២ (IP2) របស់អង្គការអុកស្វាម ត្រូវបានអនុវត្តតាំងពីពាក់កណ្តាលឆ្នាំ ២០២០ តាមរយៈភាពជាដៃគូរវាងអង្គការអុកស្វាម និងអង្គការទន្លេអន្តរជាតិ (IR) បន្តពីជំហានទី១ (IP1) ដែលបានអនុវត្តចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ ក្រោមមូលនិធិគាំទ្រពី DFAT ក្នុងទឹកប្រាក់សរុបចំនួន ៩ លានដុល្លារ អូស្រ្តាលី ដែលជាការវិនិយោគស្នូលរបស់ DFAT តាមរយៈកម្មវិធីធនធានទឹកក្នុងតំបន់មេគង្គ (Greater Mekong Water Resources Program ២០១៦-២០២០ (GMWRP) ដែលក្នុងនោះអង្គការ Oxfam ជាភ្នាក់ងារអនុវត្តគម្រោងតែមួយគត់។

ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្រ្តាលី (DFAT) ផ្តល់ហិរញ្ញប្បទានដើម្បីអនុវត្តគម្រោង IP2 និងក្រោយមកត្រូវបានគាំទ្រដោយទីភ្នាក់ងារស្វីសសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ (SDC) ចាប់ពីឆ្នាំ២០២១។ ថេរៈវេលាដើមក្នុងការអនុវត្តគម្រោង គឺពីខែមិថុនា ឆ្នាំ២០២០ ដល់ខែមិថុនា ឆ្នាំ២០២៤ ប៉ុន្តែក្រោយមកត្រូវបានព្រមព្រៀងពន្យារពេលដោយមិនមានផ្តល់ថវិកាបន្ថែម រហូតដល់ ខែមេសា ឆ្នាំ២០២៥។ ថវិកាវិនិយោគសរុបក្នុងគម្រោង IP2 គឺ ៥.៤៣១.៧០៥ ដុល្លារអូស្រ្តាលី ពី DFAT និង ៣.៤៦៧.២៨១ដុល្លារអាមេរិក ពីទីភ្នាក់ងារស្វីសសម្រាប់កិច្ចសហប្រតិបត្តិ និងការអភិវឌ្ឍ (SDC)។ គម្រោងត្រូវបានអនុវត្តរួមគ្នា អង្គការអុកស្វាម និងអង្គការទន្លេអន្តរជាតិ រហូតដល់ខែមិថុនា ឆ្នាំ២០២៤ និងបន្តអនុវត្តដោយអង្គការអុកស្វាមតែមួយគត់ចាប់ពីខែកក្កដា ឆ្នាំ២០២៤ រហូតដល់ គម្រោងបញ្ចប់នាខែមេសា ឆ្នាំ២០២៥។

គម្រោងបរិយាបន្នទឹក មានគោលបំណងលើកស្ទួយអភិបាលកិច្ចទឹកប្រកបដោយ *បរិយាប័ន្ន សមធម៌ និងនិរន្តរភាព រួមចំណែកកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងបង្កើនគណនេយ្យ ភាពសង្គមចំពោះប្រជាពលរដ្ឋនៅក្នុងតំបន់មេគង្គ។* ចក្ខុវិស័យរបស់គម្រោង គឺសហគមន៍ដែលរស់នៅ ក្នុងអាងទន្លេមេគង្គ និងទន្លេសាល់វីន (Salween) យល់ដឹងអំពីសិទ្ធិរបស់ខ្លួន ក្នុងការរស់នៅប្រកប ដោយនិរន្តរភាព ។

**វិសាលភាពនៃការផ្លាស់ប្តូរដែលមានភាពប្រទាក់ក្រឡាចំនួន៣ ដែលគម្រោង IP2 ចង់សម្រេចឱ្យបាន រួមមាន៖**

១. បរិយាបន្នសង្គម សមភាពយេនឌ័រ និងស្រ្តីក្នុងភាពជាអ្នកដឹកនាំ
២. ការចូលរួម និងចងក្រងជាបណ្តាញរបស់សង្គមស៊ីវិល
៣. ការគាំទ្រនិងកិច្ចសហការរបស់រដ្ឋាភិបាល និងវិស័យឯកជន។

ចំណុចទាំងបីនេះ ត្រូវបានបកស្រាយលម្អិតដូចខាងក្រោម៖

**គោលបំណងនៃការវាយតម្លៃ៖** ការវាយតម្លៃបញ្ចប់គម្រោង មានគោលបំណងដូចខាងក្រោម៖

១. វាយតម្លៃផលប៉ះពាល់នៃគម្រោងបរិយាបន្នទឹក ដំណាក់កាលទី២ ផ្អែកតាមទ្រឹស្តីនៃការផ្លាស់ប្តូរ (Theory of Change) និងទ្រឹស្តីនៃសកម្មភាព (Theory of Action) ស្របតាមការកែសម្រួលលើការពន្យារពេលគម្រោងដោយមិនមានបន្ថែមថវិកា រហូតដល់ខែមេសា ឆ្នាំ២០២៥។

២. វាយតម្លៃលើវិសាលភាពរបស់អភិក្រមនិងយុទ្ធសាស្រ្តគម្រោង ក្នុងការរួមចំណែកសម្រេចបានលទ្ធផលចុងក្រោយនិងឥទ្ធិពលរបស់គម្រោង។

៣. កត់ត្រាមេរៀនដកស្រង់និងបទពិសោធន៍ រួមទាំងអនុសាសន៍ ដើម្បីជាប្រយោជន៍ដល់អង្គការអុកស្វាម អង្គការទន្លេអន្តរជាតិ និងដៃគូរបស់ខ្លួន យកទៅប្រើប្រាស់បន្តក្នុងកម្មវិធីអភិវឌ្ឍន៍នាពេលអនាគត។

ក្រុមអ្នកវាយតម្លៃ ធ្លាប់មានបទពិសោធន៍ការងារពីមុនជាមួយអង្គការអុកស្វាមលើការងារអភិបាលកិច្ច និងបរិយាប័ន្នទឹកក្នុងមហាអនុតំបន់ទន្លេមេគង្គ មានគ្នាបីរូប ដឹកនាំដោយ Mark Deasey (ប្រធានក្រុម) Bounthavivanh Mixap និង Vo Thi Tam ទទួលភារកិច្ចវាយតម្លៃនាពេលនេះ។

**វិធីសាស្ត្រ៖** អង្គភាពគ្រប់គ្រងគម្រោង IP2 (PMU) ទទួលខុសត្រូវពិនិត្យមើលការវាយតម្លៃជារួម ក្រោមការចង្អុលបង្ហាញដោយប្រយោលពីតំណាងមកពី DFAT, SDC, Oxfam និងទន្លេអន្តរជាតិ។ ក្រុមការងារវាយតម្លៃ ចាប់ផ្តើមដោយសរសេរជាទម្រង់របាយការណ៍បឋម ព្រមទាំងការពិនិត្យមើលលម្អិតនិងស៊ីជម្រៅលើរបាយការណ៍គម្រោងផ្សេងៗ និងការប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងតំបន់។ ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះដោយផ្ទាល់ (KIIs) និងក្រុមពិភាក្សា (FGDs) ជាពិសេសសហគមន៍ទទួលផល ត្រូវបានធ្វើឡើងនៅក្នុងប្រទេសវៀតណាមនិងកម្ពុជា។ សម្រាប់ប្រទេសឡាវ ដោយសារតែពុំមានអនុស្សរណៈនៃការយោគយល់ជាផ្លូវការ ទិន្នន័យត្រូវបានប្រមូលតាមរយៈ KIIs និងកិច្ចសម្ភាសជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ នៅទីក្រុងវៀងចន្ទន៍ និងហ្លួងព្រះបាងភាគច្រើន។ សម្រាប់ភាគីថៃ កិច្ចសម្ភាសន៍គឺធ្វើឡើងតាមអនឡាញ។

ស្របតាមគោលបំណង និងរចនាសម្ព័ន្ធរបស់គម្រោង IP2 ទស្សនទាននិងការយល់ដឹងអំពីយេនឌ័រ ត្រូវបានបញ្ចូលទៅក្នុងការវាយតម្លៃ រួមទាំងការប្រើប្រាស់ពាក្យពេជន៍យ៉ាងទូលំទូលាយ។

**ដែនកំណត់៖** ចំណុចសំខាន់ៗ ដែលត្រូវបានយកមកពិចារណារួមមាន៖

- ការប្រាស័យទាក់ទងជាមួយភាគីពាក់ព័ន្ធនៅក្នុងតំបន់ រួមនិងវិសាលភាពការងារនៅក្នុងប្រទេសនីមួយៗមានទំហំខុសគ្នា បន្ថែមទាំងកត្តារឹតបន្តឹងលើការធ្វើដំណើរ និងចុះទៅកាន់ទីតាំងគម្រោងដោយផ្ទាល់ គឺពុំអាចធ្វើបានដូចគ្នា ឬឱ្យមានតុល្យភាពនោះឡើយ។ ដោយហេតុនេះ ការសម្ភាសភាគីពាក់ព័ន្ធនៅតាមទីតាំងទាំងនោះ ភាគច្រើនត្រូវបានសម្រួលដោយប្រើប្រាស់ការប្រាស្រ័យទាក់ទងតាមអ៊ីនធឺណិត។
- មិនខុសពីការចងក្រងនៅក្នុងឯកសារអនុវត្តគម្រោងទាំងពីរជំហាន IP1 និង IP2 យើងនៅតែប្រឈមជាមួយការលំបាកក្នុងការទទួលបានធាតុចូលដោយផ្ទាល់ពីតួអង្គវិស័យឯកជន។
- ការសម្ភាសន៍ជាមួយតួអង្គពីស្ថាប័នរដ្ឋាភិបាលគឺតិចជាងការរំពឹងទុក ទោះបីជាបានទទួលទិន្នន័យសំខាន់ៗពីមន្ត្រីថ្នាក់ក្រោមជាតិនៅក្នុងប្រទេសឡាវ និងវៀតណាម និងពីមន្ត្រីថ្នាក់ជាតិនៅក្នុងប្រទេសកម្ពុជាក៏ដោយ។
- ក្រុមការងារព្យាយាមសម្ភាសន៍ឱ្យបានច្រើនផងដែរ តែពុំអាចធ្វើទៅបាន ជាពិសេសការយល់ដឹងអំពីសកម្មភាពរបស់គម្រោង IP2 នៅកម្រិតតំបន់គឺមានតិចតួច ដោយក្នុងនោះមានពីរនាក់ជាមន្ត្រីរដ្ឋាភិបាល។
- ដោយសារកត្តាពេលវេលា និងថវិកាមានកំណត់ ក្រុមការងារវាយតម្លៃមិនអាចជួបប្រជុំដោយផ្ទាល់បានឡើយនៅក្នុងកិច្ចដំណើរការទាំងមូល។ ការប្រាស្រ័យទាក់ទងតាមអនឡាញជាលាយលក្ខណ៍អក្សរ និងសម្លេង ជួយសម្រួលកិច្ចការមួយផ្នែកយ៉ាងធំផងដែរ។

**ការឈ្វេងយល់និងពិនិត្យមើលឯកសារ៖** របាយការណ៍ និងឯកសាររបស់គម្រោង IP2 ត្រូវបានចងក្រង យ៉ាងទូលំទូលាយ និងវិភាគស៊ីជម្រៅបើធៀបទៅនឹងដំណាក់កាលទីមួយ (២០១៦ – ២០២០)។ ការវិភាគផ្នែកនយោបាយ និងសេដ្ឋកិច្ច (PEA) ក្នុងបរិបទនៃកិច្ចប្រតិបត្តិការនៅក្នុងអនុតំបន់មេគង្គ ទាំងច្បាប់ដើម និងកំណែប្រែថ្មីក្នុងខែឧសភា ឆ្នាំ២០២៤ បានផ្តល់ព័ត៌មានដ៏មានតម្លៃបម្រើដល់ការ វាយតម្លៃជារួម ជាពិសេសឯកសារជាក់លាក់សម្រាប់បង្កើតផែនការ GEDSI និងសេចក្តីណែនាំអំពី ការកត់ត្រាលទ្ធផល ដែលជាផ្នែកមួយនៃក្របខ័ណ្ឌត្រួតពិនិត្យ វាយតម្លៃ និងដកស្រង់មេរៀន (MEAL) ត្រូវបានយកមកប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព។ ឆ្លងតាមការពិនិត្យមើលឯកសារ ឡើងវិញ បរិបទនិងធាតុផ្សំសំខាន់ពាក់ព័ន្ធទៅនឹងការអនុវត្តគម្រោងរួមមាននិន្នាការប្រើប្រាស់អំណាច ផ្តាច់ការរបស់រដ្ឋាភិបាល ការប្រមូលផ្តុំអំណាចនៅថ្នាក់កណ្តាល និងការរឹតបន្តឹងលំហសង្គមស៊ីវិល បន្ថែមលើភាពធន់និងការច្នៃប្រឌិតរបស់តួអង្គសង្គមស៊ីវិល ក្នុងការសម្របខ្លួនទៅនឹងបរិយាកាស ផ្លាស់ប្តូរ និងភាពរហ័សរហួនរបស់ដៃគូ IR, Oxfam និង IP2 ក្នុងប្រើប្រាស់និងទាញយកប្រយោជន៍អំពី បណ្តាញនិងវេទិកាដែលមានស្រាប់។ ការលេចឡើងនូវបច្ចេកវិទ្យាបង្កើតថាមពលកកើតឡើងវិញ ដែលមិនប្រើវារីអគ្គិសនី (RE) មានភាពជាសារវ័ន្ត និងជាកត្តាបន្ទុចបង្អាក់ដល់ការអភិវឌ្ឍថាមពល វារីអគ្គិសនី និងឥន្ធនៈហ្វូស៊ីល ដែលបានរួមចំណែកលើកកម្ពស់ការយល់ដឹងរបស់រដ្ឋាភិបាល និង សាធារណៈជនទូទៅអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ប្រព័ន្ធទន្លេ និងទិដ្ឋភាពឯទៀត។

ក្រុមការងារវាយតម្លៃ បានសាកសួរអ្នកផ្តល់ព័ត៌មានសំខាន់ៗអំពីបទពិសោធន៍នៃការអនុវត្តគម្រោង ផ្អែកលើទ្រឹស្តីនៃការផ្លាស់ប្តូរ (ToC) និងទ្រឹស្តីនៃសកម្មភាព (ToA) បន្ថែមលើឯកសារ PEA ទាំងច្បាប់ដើម និងកំណែប្រែថ្មី។ ចំណុចលម្អិតគឺមានបង្ហាញនៅក្នុងលទ្ធផល និងការរកឃើញ ។ ក្នុង ន័យទូលាយ យុទ្ធសាស្ត្រអនុវត្តគម្រោងហាក់មានភាពសមស្រប បើទោះជាស្រពិចស្រពិលដោយអន្លើ តែមានភាពភាពបត់បែនខ្ពស់។ លទ្ធផលទាំង៣ សម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់  បើទោះជា លទ្ធផលទី៣ ដែលមិនបានកំណត់ពី៨ឆ្នាំដំបូងមក ស្តីពីការប្តេជ្ញាចិត្តរបស់តួអង្គរដ្ឋ និងវិស័យឯកជន ក្នុងការអនុលោមភាពតាមស្តង់ដារអន្តរជាតិក្នុងការផលិតថាមពលវារីអគ្គិសនី និងថាមពលកកើត ឡើងវិញ វាហាក់ដូចជាមានសុទិដ្ឋិនិយមនៅក្នុងបរិបទនយោបាយ និងសេដ្ឋកិច្ចតំបន់នាពេលបច្ចុប្បន្ន ដែលយើងអាចរំពឹងពីវឌ្ឍនភាពនាឆ្នាំខាងមុខៗទៀតបាន។

**កំណត់សម្គាល់ និងការរកឃើញសំខាន់ៗនៅក្នុងលទ្ធផលនីមួយៗ មានដូចតទៅ៖**

## លទ្ធផលទី ១

# ស្ត្រីមេដឹកនាំ និងតំណាងឱ្យក្រុមជនងាយរងគ្រោះ ក្នុងសង្គម កំពុងដើរតួនាទីជាអ្នកដឹកនាំ និងបង្កើតឥទ្ធិពលដល់តួអង្គរដ្ឋ និងមិនមែនរដ្ឋនៅថ្នាក់តំបន់ ក្នុងដំណើរការកសាងផែនការ និងបង្កើតគោលនយោបាយអភិបាលកិច្ចទឹក (WRG) និងថាមពល។

លទ្ធផលផ្នែកនេះរបស់គម្រោង IP2 ទទួលបានជោគជ័យខ្ពស់បំផុត ទោះបីជាប្រែប្រួលខ្លាំងទៅតាម ប្រទេសនីមួយៗក្នុងតំបន់ក៏ដោយ។ បន្តពីកិច្ចខិតខំប្រឹងប្រែងរបស់ IP1 ក្នុងការលើកស្ទួយនិងពង្រឹង តួនាទីស្ត្រីជាអ្នកដឹកនាំ ផ្នែកនេះសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុង IP2។ គម្រោង បានដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗ និងការណែនាំថ្មីៗ មកអនុវត្តជាមួយដៃគូ និងសហគមន៍ ដូចជាការស្រាវជ្រាវផ្អែកលើសកម្មភាពសហគមន៍ (CAR) ការស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម (FPAR) នៅក្នុងប្រទេសកម្ពុជា វិធីសាស្ត្រ Sao Baan ( ប្រជាជនភូមិ ) នៅក្នុងប្រទេសឡាវ វិធីសាស្ត្រ Tai Baan នៅក្នុងប្រទេសថៃ និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន ដោយប្រជាជន (EIA) សម្រាប់គម្រោងបង្វែរផ្លូវទឹក Yuam/ Salween ។ ទាំងដៃគូ សហគមន៍ និង ប្រជាពលរដ្ឋទូទៅ ទទួលស្គាល់ពីការផ្លាស់ប្តូរជាវិជ្ជមាន និងទំនុកចិត្តរបស់ស្ត្រីក្នុងតួនាទីដឹកនាំ លើកស្ទួយសាមគ្គីភាពនិងការរួបរួមរបស់សហគមន៍ និងសមត្ថភាពពាំនាំក្តីកង្វល់របស់សហគមន៍ និង ការស្វែងរកមតិគាំទ្រពីអាជ្ញាធរ ដោយប្រើសម្លេងរួម។ ទទួលស្គាល់ពីតថភាពនៃតួនាទី និងឋានៈរបស់ស្ត្រីនៅក្នុងសង្គម គម្រោងប្រើប្រាស់វិធីសាស្ត្រ សិក្សាស្រាវជ្រាវដោយមានការចូលរួមបែបមាតាធិបតេយ្យ (FPAR) និងការស្រាវជ្រាវផ្អែកលើសកម្មភាពសហគមន៍ បន្ថែមលើយុទ្ធសាស្ត្រជាក់លាក់ គ្រប់ជ្រុងជ្រោយដើម្បីបន្តពង្រឹងភាពធន់ទ្រាំ និងអភិវឌ្ឍន៍តួនាទីស្ត្រី ក្នុងភាពជាអ្នកដឹកនាំ។ ធាតុសំខាន់មួយក្នុងយុទ្ធសាស្ត្រនេះ គឺការបង្កើតបណ្តាញស្ត្រីថ្នាក់ដឹកនាំថ្នាក់ជាតិ និងថ្នាក់តំបន់។



Asia Women and Rivers Congress in Chaing Rai, Thailand


Women of Kon Mom community fishery in Cambodia

អង្គការសង្គមស៊ីវិលនិងដៃគូដទៃទៀត ក៏បានលើកឡើងផងដែរអំពីវឌ្ឍនភាពក្នុងការប្រើប្រាស់និង វាយការណ៍ពីការវិភាគយេនឌ័រ និងឥទ្ធិពលនៅក្នុងការងាររបស់ខ្លួន។ ថ្វីត្បិតតែទាបជាងចំណុចដៅដំបូងដែលបានកំណត់ទុក អង្គភាពរដ្ឋ និងផ្នែកឯកជន ប្រើប្រាស់ការវាយតម្លៃផលប៉ះពាល់យេនឌ័រ នៅក្នុងការកសាងផែនការ និងយុទ្ធសាស្ត្ររបស់ខ្លួន។

គម្រោងក៏បានផ្តល់លទ្ធភាពឱ្យមានការដាក់បញ្ចូលស្ត្រីវ័យក្មេង និងស្ត្រីជនជាតិដើមភាគតិចនៅក្នុងអង្គការសហគមន៍ និងភាពជាអ្នកដឹកនាំ ផ្អែកតាមគោលការណ៍សមាមាត្រ និងមានភាពប្រទាក់ក្រឡា ត្រឹមត្រូវ។ ការដាក់បញ្ចូលជនមានពិការភាព (PwD) និងក្រុមមនុស្សមាននិន្នាការភេទចម្រុះ (SOGIE) ពុំសូវមានសង្គតិភាពនោះទេ ប៉ុន្តែយើងបានកត់សម្គាល់អំពីគំនិតផ្តួចផ្តើមសំខាន់ៗ និងសមិទ្ធិផលមួយចំនួន ដែលអាចជាមូលដ្ឋានសម្រាប់ពង្រីកការអនុវត្តល្អប្រសើរ និងកិច្ចខិតខំប្រឹងប្រែង បែបនេះឱ្យកាន់តែមានភាពទូលំទូលាយជាងមុនទៀតនាពេលអនាគត។

សមិទ្ធិផលគឺមិនសម្រេចបានដូចគ្នាទាំងអស់ទេនៅទូទាំងតំបន់ ដោយសារកត្តារួមផ្សំមួយចំនួនដូចជាការត្រួតពិនិត្យ និងឃ្លាំមើលរបស់រដ្ឋាភិបាលលើលំហបណ្តុះបណ្តាល រួមទាំងកត្តាសន្តិសុខ និងការ យល់ដឹងពីគោលការណ៍សមភាពយេនឌ័ររបស់ដៃគូ និងសហគមន៍នៅមានកម្រិត។ ទន្ទឹមនឹងនេះ គេសង្កេតឃើញថាស្ត្រីជាអ្នកដឹកនាំបានចូលរួមយ៉ាងសកម្ម និងមានភាពស៊ីសង្វាក់ជាមួយអាជ្ញាធរ រដ្ឋបាលថ្នាក់ក្រោមជាតិ និងតួអង្គសំខាន់ៗលើការងារអភិបាលកិច្ចទឹក និងធនធានផ្សេងៗរហូតមក ដល់ពេលនេះ  ខណៈដែលក្តីកង្វល់និងចំណេះដឹងក្នុងស្រុក ត្រូវបានប្រើប្រាស់បម្រើឱ្យការងារតស៊ូមតិ ទាំងនៅថ្នាក់ជាតិនិងថ្នាក់តំបន់។ នៅក្នុងប្រទេសថៃ ការចូលរួមរបស់ស្ត្រីមេដឹកពីបណ្តាអង្គការដៃគូ និងសហគមន៍ជាមួយស្ថាប័នរដ្ឋាភិបាល ផ្នែកច្បាប់ និងវិស័យឯកជន គឺមានភាពលេចធ្លោរ ដោយសារអង្គការសហគមន៍មានប្រវត្តិដ៏យូរអង្វែងមកហើយ ក្នុងការរៀបចំឱ្យមានលំហសម្រាប់តស៊ូ មតិ និងបង្កើតឥទ្ធិពល។ សម្រាប់ការងារនាពេលអនាគតលើបរិយាប័ន្ននិងអភិបាលកិច្ចធនធានទឹក ការផ្សារភ្ជាប់ទំនាក់ទំនងប្រកបដោយសង្គតិភាព ដើម្បីបង្កើតផលជះជាកិច្ចការ ចាំបាច់និងអាទិភាព។

**លទ្ធផលទី ២**

## សហគមន៍តាមដងទន្លេ និងតួអង្គសង្គមស៊ីវិលចូលរួមយ៉ាងសកម្មក្នុងដំណើការកសាង ផែនការ និងបង្កើតឥទ្ធិពលលើគោលនយោបាយអភិបាលកិច្ចធនធានទឹក (WRG) នៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងថ្នាក់តំបន់ និងលើកកម្ពស់សិទ្ធ និងឧត្តមប្រយោជន៍របស់ក្រុមងាយរងគ្រោះ។

ពេញមួយវដ្តគម្រោង IP2 យើងកត់សម្គាល់ឃើញថា ការចូលរួមដោយផ្ទាល់ក្នុងការធ្វើផែនការ និងតាក់តែងគោលនយោបាយ WRG ទាំងនៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងថ្នាក់តំបន់ ត្រូវបានធ្វើ ឡើងដោយបើកចំហ មានភាពស្វាហាប់ និងសង្គតិភាព។ ចំពោះឥទ្ធិពល យើងពិបាកនឹងបញ្ជាក់ ឬមានភាពប្រាកដប្រជា ថាសម្រេចបានប៉ុណ្ណានោះទេមកទល់ពេលនេះ។ សម្រាប់លទ្ធផលទី១ ខាងលើ យើងហ៊ានអះអាងអំពីការចូលរួម និងឥទ្ធិពលកម្រិតមធ្យមដែលត្រូវបានកត់សម្គាល់ ជាពិសេស រវាងថ្នាក់មូលដ្ឋាននិងថ្នាក់ក្រោមជាតិ។ ឧទាហរណ៍អំពីការចូលរួមដោយផ្ទាល់ពីសហគមន៍ និងអង្គការ សង្គមស៊ីវិលជាមួយថ្នាក់ជាតិត្រូវបាន កត់សម្គាល់ ក៏ដូចជាវឌ្ឍនភាពក្នុងការផ្សារភ្ជាប់ពី



learning exchange on communication action research in Cambodia

កម្រិតមូលដ្ឋាន ទៅថ្នាក់ជាតិនិងថ្នាក់តំបន់ ក្រោមឆ័ត្ររបស់អង្គការសង្គមស៊ីវិល ដោយផ្តល់ឱកាសឱ្យស្ត្រី និងអ្នកដឹកនាំសហគមន៍ផ្សេងទៀតបានចូលរួមនៅក្នុងវេទិកាថ្នាក់ជាតិ និងថ្នាក់តំបន់។




Nine journalists from Thailand, Cambodia, Laos, Myanmar and Vietnam have been trained in reporting on GEDSI issues in water governance in October 2023, Thailand.

## ប្រភពនៃការទំនាក់ទំនង និងការឆ្លើយតប ត្រូវបានវាយតម្លៃផ្អែកលើយុទ្ធសាស្ត្រសំខាន់ៗថ្មីៗ ដែលត្រូវបានយកមកប្រើប្រាស់ ដូចជា៖

- ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងទំនើបប្រកបដោយប្រសិទ្ធភាព ដើម្បីបំពង សម្លេងរបស់សហគមន៍ តាមរយៈជំនួបប្រជុំជាទៀងទាត់ ដំណើរទស្សនកិច្ចឈ្វេងយល់របស់ អ្នកកាសែតស្របតាមលក្ខខណ្ឌអំណោយផល និងវត្តមានរបស់ស្ត្រីគាំទ្រដោយគម្រោង IP2 ក្នុងកម្មវិធីសម្លេងស្ត្រី តាមរយៈវិទ្យុសម្លេងស្ត្រីឯករាជ្យនៅកម្ពុជា បើទោះជាលំហសារព័ត៌មាន នេះមានកំហិតកំណត់ក៏ដោយ ប៉ុន្តែជាវាំច្រកចេញដែលស្ត្រីថ្នាក់ដឹកនាំសហគមន៍អាចលើក ឡើងអំពីសម្លេង និងក្តីកង្វល់របស់ខ្លួនជូនសាធារណជនយល់ជ្រាបបាន។ “ការស្វែងរកមតិ គាំទ្រផ្អែកទន់” ត្រូវបានធ្វើឡើងដោយប្រើប្រាស់បណ្តាញសង្គមដើម្បីបំពេញបន្ថែម ដើម្បីឆ្លុះបញ្ចាំងអំពីការទទួលស្គាល់របស់រដ្ឋាភិបាលចំពោះក្តីកង្វល់របស់ពលរដ្ឋ បើទោះជាលំហ ប្រជាធិបតេយ្យពុំសូវជាទូលំទូលាយក៏ដោយ។
- ការបង្កើតនិងប្រើប្រាស់ភស្តុតាង ជាមូលដ្ឋានលើកកម្ពស់ការចូលរួមរបស់សហគមន៍ មានភាពជាសារវ័ន្ត ជាពិសេសវិធីសាស្ត្រមួយចំនួនដូចជា FPAR, Sao Baan និង People’s EIA បន្ថែមលើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋនិងគ្រឹះស្ថានសិក្សាស្រាវជាវ។
- ទំនាក់ទំនងជាមួយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ( និងដៃគូអភិវឌ្ឍន៍របស់ MRC ជាពិសេស TROIKA) និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានភាព បើកទូលាយ និងស៊ីជម្រៅ ជាពិសេសការទទួលយកសម្លេងសង្គមស៊ីវិល។ យើងអាចសន្និដ្ឋាន បានថាទាំង IR, Oxfam និងអង្គការដៃគូ សម្រេចបានលទ្ធផលនិងផលជះ តាមរយៈកិច្ចសហការយ៉ាងបើកចំហ អាចថាជាឥទ្ធិពលពីដៃគូមូលនិធិរបស់ MRC ផងដែរ។

## លទ្ធផលទី ៣

# តួអង្គពីវិស័យឯកជន និងស្ថាប័នរដ្ឋដៃគូទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ប្តេជ្ញាចិត្តខ្ពស់ ក្នុងការអនុលោមតាមការអនុវត្តល្អ និងស្តង់ដារថ្នាក់តំបន់និងអន្តរជាតិ និងដាក់បញ្ចូលទស្សនៈរបស់ សង្គមស៊ីវិលនៅក្នុងគោលនយោបាយនិងផែនការស្តីពីថាមពលវារីអគ្គិសនី និងថាមពលពលកកើតឡើងវិញ។




Mekong Fair in Chiang Kong where a representative from Chinese Embassy was on the panel with Thai academics and Thai Member of the parliament in December 2023

ឆ្លងកាត់ការពិនិត្យឯកសារនិងកិច្ចសម្ភាសជាមួយភាគីពាក់ព័ន្ធសំខាន់ៗ យើងពុំអាចស្វែងរកភស្តុតាង រឹងមាំសបញ្ជាក់ពីអនុលោមភាពដែលប្រតិបត្តិដោយស្ថាប័ន រដ្ឋាភិបាលនិងវិស័យឯកជន នៅក្នុង គម្រោង IP2 បើទោះជាលទ្ធផលនេះចាំបាច់ត្រូវពិនិត្យមើលក្នុងរយៈពេល៨ឆ្នាំនៃវដ្តគម្រោង។ បីជាកត់សម្គាល់ថាលទ្ធផលនេះត្រូវបានកំណត់ជាមួយនឹងរយៈពេលប្រាំបីឆ្នាំ ។ ផ្អែកលើ NCE យើង កត់សម្គាល់ឃើញវឌ្ឍនភាពគួរឱ្យកត់សម្គាល់មួយចំនួនដែលនឹងត្រូវរៀបរាប់លម្អិតដូចខាងក្រោម លើ ផ្នែកការប្តេជ្ញាចិត្តនៃអនុលោមភាព។ សម្រាប់ការត្រួសត្រាយផ្លូវ យើងឃើញថាមានវឌ្ឍនភាពលើផ្នែក ជាច្រើន ជាពិសេសការបើកច្រកសម្រាប់កិច្ចសន្ទនានិងឥទ្ធិពល ដែលនឹងអាចសម្រេចបានជាដុំកំភួន នាពេលអនាគត  ខណៈដែលលទ្ធិប្រជាធិបតេយ្យត្រូវបានរដ្ឋាភិបាលបើកចំហកាន់តែខ្លាំង ជាពិសេសនៅពេលដែលលទ្ធផលសារពើរពន្ធមិនគាប់ប្រសើរ ពីការវិនិយោគថាមពលវារីអគ្គិសនីត្រូវបានបង្ហាញ ឱ្យឃើញកាន់ច្បាស់ ឬសាធារណជនដាក់សម្ពាធកាន់តែខ្លាំង ដោយសារការព្រួយបារម្ភនិងការ យល់ដឹងកាន់តែទូលំទូលាយអំពីជម្រើសផ្សេងៗនៃនិរន្តរភាពថាមពល។

## បទពិសោធន៍សំខាន់ៗពីគម្រោង IP2 មានដូចតទៅ៖

- សមភាពយេនឌ័រ និង GEDSI គឺជាចំណុចរសើប និងទទួលបានការស្វាគមន៍កាន់តែខ្លាំងពីរដ្ឋាភិបាលនៅទូទាំងតំបន់ សម្រាប់ដាក់បញ្ចូលទៅក្នុងគោលនយោបាយលើបញ្ហាជាច្រើន។
- ធនាគារថៃទទួលយក និងពិចារណាខ្ពស់ លើផលប៉ះពាល់ផ្នែកបរិស្ថាននិងហានិភ័យហិរញ្ញវត្ថុក្នុងការអភិវឌ្ឍវារីអគ្គិសនី។
- ច្រកក្នុងការទំនាក់ទំនងជាមួយរដ្ឋាភិបាលជាតិឡាវប្រកបដោយឥទ្ធិពលថ្មីៗ ត្រូវបានបង្កើត បើទោះមានការរឹតបន្តឹងលើលំហសង្គមស៊ីវិលក៏ដោយ។
- ការទទួលយករបស់រដ្ឋាភិបាលកម្ពុជាចំពោះគំនិតផ្តួចផ្តើមថាមពលកកើតឡើងវិញផ្សេងទៀតក្រៅអំពីវារីអគ្គិសនី ទាំងគម្រោងខ្នាតធំ និងប្រើប្រាស់ក្នុងសហគមន៍។
- បណ្តាញទំនាក់ទំនងចម្រុះនិងឥទ្ធិពលមានលើតួអង្គនិងស្ថាប័នថៃ  ពាក់ព័ន្ធទៅនឹងផែនការនិងគម្រោងវិនិយោគក្រៅស្រុករបស់ប្រទេសរបស់ថៃ និងផលប៉ះពាល់ឆ្លងដែនលើពលរដ្ឋថៃ។
- ស្ថាប័នមានសមត្ថកិច្ចរបស់ថៃមានកាតព្វកិច្ចត្រួតពិនិត្យ និងលើកឡើងពីបញ្ហាផលប៉ះពាល់ឆ្លងដែនលើប្រជាជនថៃ បង្កពីគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅកន្លែងផ្សេងទៀត។

គម្រោង IP2 ចាប់ផ្តើមធ្វើការលើផ្នែកគោលនយោបាយថ្នាក់ជាតិ និងថ្នាក់តំបន់ស្តីពីថាមពលកកើត ឡើងវិញ (RE) ក្នុងឆ្នាំ២០២១ ប៉ុន្តែគំនិតផ្តួចផ្តើមសំខាន់ៗនៅថ្នាក់មូលដ្ឋានទើបចាប់ផ្តើមក្នុងឆ្នាំ ២០២៣ ប៉ុណ្ណោះ ដោយពុំទាន់សម្រេចបានលទ្ធផលច្រើនទេមកដល់ពេលនេះ។ សូមកត់សម្គាល់ថា អង្គភាពអនុវត្តគម្រោង (IP2 PMU) បានដាក់បញ្ចូលធាតុផ្សំសំខាន់ៗស្តីពី RE ទៅក្នុងគំនិងផ្តួចផ្តើម ផ្សេងទៀតក្រៅពីគម្រោង IP2 ដែលជាការអនុវត្តបំពេញបន្ថែមដោយ Oxfam និងដៃគូ។



The NHRC investigative meeting on Pak Beng dam in Chiang Kong, September 2023

អភិក្រមដែល IR, Oxfam និងអង្គការដៃគូ ប្រើប្រាស់ក្នុងការអនុវត្តគម្រោង IP2 ទទួលបានការសាទរ ពីតួអង្គខាងក្រៅជាច្រើន ជាពិសេសយុទ្ធសាស្ត្រ និងបណ្តាញទំនាក់ទំនងផ្នែក RE ដែលនឹងអាច យកទៅអនុវត្តបន្ត ដោយភាពជឿជាក់ក្នុងការបង្កើតផលជះទាំងផ្នែកគោលនយោបាយ និងកិច្ចប្រតិបត្តិជាក់ស្តែង។

## ការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យ OECD-DAC៖

**ការរៀបចំ គ្រប់គ្រង និងអភិក្រម** ក្នុងការអនុវត្តគម្រោងគឺផ្អែកតាមគោលការណ៍ខាងក្រោមជាចម្បង៖

**ប្រសិទ្ធភាព** និង **ប្រសិទ្ធផល** កិច្ចខិតខំប្រឹងប្រែងរួមរបស់ IR និង Oxfam ក្នុងការអនុវត្តគម្រោង គឺជា តម្លៃបន្ថែមដ៏ខ្ពស់បំផុត ផ្អែកលើភាពខ្លាំងដែលបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក រួមនិងបទពិសោធន៍ ស៊ីជម្រៅ បណ្តាញនិងភាពជាដៃគូយូរអង្វែងនៃការចូលរួមរបស់សហគមន៍នៅថ្នាក់តំបន់។ ទោះយ៉ាង ណាក៏ដោយ រចនាសម្ព័ន្ធរបស់បណ្តាញហាក់មានភាពស្មុគស្មាញ និងចំណាយប្រតិបត្តិការខ្ពស់។ ការគាំទ្រពី SDC និង DFAT បានពង្រីកមូលដ្ឋានធនធាន ដោយបានផ្សារភ្ជាប់ទំនាក់ទំនងជាមួយ គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ផ្សេងទៀតនៅក្នុងតំបន់ និងពង្រីកវិសាលភាពរបស់គម្រោង ប៉ុន្តែទាមទារ ធនធានផ្នែកគ្រប់គ្រងខ្ពស់ ស្របតាមលក្ខខណ្ឌតម្រូវផ្នែកគណនេយ្យភាព។

ភាពស្មុគស្មាញនៃនិម្មាបនកម្មផ្ទៃក្នុងរបស់ Oxfam បង្កភាពប្រទាំងប្រទើសមួយចំនួនផ្នែកប្រសិទ្ធិផលការងារជាពិសេសទំនាក់ទំនងរវាង PMU និងក្រុមការងារប្រចាំប្រទេស។ នៅប្រទេសឡាវ ការណ៍នេះបានកាត់បន្ថយឥទ្ធិពល និងប្រសិទ្ធិភាពរបស់គម្រោង ខណៈដែលនិរន្តរភាពតម្រូវឱ្យមាន ចំណាយប្រតិបត្តិការខ្ពស់។

<u>សង្គតិភាព</u> នៅតែជាចំណោទបញ្ហា ដោយហេតុថាវិសាលភាពនិងការអនុវត្តនៅតាមបណ្តាប្រទេស នីមួយៗក្នុងតំបន់មានសភាពខុសគ្នា  ហើយទំនាក់ទំនងពីថ្នាក់មូលដ្ឋានទៅថ្នាក់ជាតិ និងថ្នាក់តំបន់ ក៏ខុសគ្នាដែរ។ ការវាយតម្លៃរកឃើញថាអន្តរាគមន៍ដែលបែកខ្ញែក ត្រូវបានច្របាច់បញ្ចូលគ្នា ទាមទារឱ្យមានការកែសម្រួលបន្ថែមសម្រាប់កិច្ចការខាងមុខ បើទោះជាបានកំពុងដោះស្រាយខ្លះ ហើយក៏ដោយ។ ស្ត្រីនិងនិងបុរសនៅថ្នាក់មូលដ្ឋាន ទទួលស្គាល់អំពីកាលៈទេសៈ និងអាទិភាពចំពោះ មុខសហគមន៍ខ្លួន។ ភាពរស់រវើកនៃបណ្តាញ និងការចូលរួមរបស់ថ្នាក់ដឹកនាំពីថ្នាក់មូលដ្ឋាន ដល់ថ្នាក់ ជាតិ និងតំបន់ គឺជាតឹកតាងបញ្ជាក់អំពីក្របខណ្ឌនេះ។

ការយល់ដឹងអំពីនិរន្តរភាព ត្រូវបានជ្រួតជាប្រ ជាពិសេសតាមរយៈការវិនិយោគនិងផ្តល់ភាពអង់អាច ដល់សហគមន៍មូលដ្ឋាន អង្គការនិងបណ្តាញ កិច្ចគាំទ្រគ្នាទៅវិញទៅមក  ការទាញយកប្រយោជន៍ ពីចំណេះដឹងនិងជំនាញរបស់អង្គការ Oxfam និង IR ក្នុងតំបន់។ ទោះជាបែបនេះក្តី យើងមើលឃើញ ច្បាស់ថាដើម្បីថែរក្សាការរីកចម្រើននេះតទៅមុខទៀត ទាមទារឱ្យមានការផ្តល់ធនធានបន្ថែមពីតួអង្គ ផ្សេងៗក្នុងមូលដ្ឋាន ក៏ដូចជាបណ្តាញ។ ត្រូវប្រឹងប្រែងស្វែងរកមតិគាំទ្របន្ថែមទៀតពីរដ្ឋាភិបាល ក្នុងការគាំទ្រដល់ស្ថាប័នក្នុងមូលដ្ឋាន ដើម្បីសម្របខ្លួនទៅនឹងគោលនយោបាយរបស់រដ្ឋ។ អង្គការដៃគូ អាចបន្តប្រតិបត្តិការរបស់ខ្លួននៅក្នុងសហគមន៍ អាស្រ័យទៅលើសមត្ថភាពផ្ទាល់ខ្លួនក្នុងការឆ្លើយតប ទៅនឹងបញ្ហាប្រឈមផ្នែកជីវភាពរស់រយៈពេលខ្លី ក៏ដូចជាឥទ្ធិពលរយៈពេលមធ្យម។

**ភាពពាក់ព័ន្ធ** របស់គម្រោងគឺច្បាស់លាស់ណាស់ ដូចការគូសបញ្ជាក់ពីភាគីពាក់ព័ន្ធ។ ថ្វីត្បិតតែនៅ មានភាពមិនប្រាកដប្រជាមួយចំនួន លើការសម្រេចបានលទ្ធផលទី ៣ – ជាតួយ៉ាង ដោយការ សន្មត់ថាគម្រោងត្រូវពន្យារពេលបន្ថែមឱ្យដល់៨ឆ្នាំ - រួមទាំងនិន្នាការនយោបាយក្នុងតំបន់ និងជវភាព នៃការប្រែប្រួលក្នុងតំបន់ ការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី  ការដាក់បញ្ចូលសហគមន៍ដែល ងាយរងគ្រោះ និងក្រុមប្រជាជនគន្លឹះ នឹងនៅតែមានភាពជាសារវ័ន្ត ដោយពុំអាចខ្វះបាន។

# អនុសាសន៍៖

សន្ទត់ថាម្ចាស់ជំនួយសំខាន់ៗនៅតែបន្តផ្តល់មូលនិធិគាំទ្រមិនត្រឹមតែសម្រាប់អនុវត្តគម្រោងបរិយាបន្នទឹក តែកម្មវិធីថ្នាក់តំបន់ផ្សេងទៀតដែលមានភាពប្រទាក់ក្រឡា យើងអាចផ្តល់នូវអនុសាសន៍ ដូចតទៅ ៖

អនុសាសន៍ទាំងនេះគឺផ្អែកលើចំណុចខ្លាំងសំខាន់ៗដែលបានអនុវត្តនៅក្នុងគម្រោង IP2 ទាំងចំណុច ល្អប្រសើរ ដែលត្រូវរៀនសូត្រ និងអនុវត្តនាពេលអនាគត និងចំណុចត្រូវកែលម្អ។ **យើងពុំបានដាក់ បញ្ចូលរាល់គ្រប់ទិដ្ឋភាព និងការអនុវត្តនៅក្នុងគម្រោង IP2 ដើម្បីធ្វើសេចក្តីសំយោគនោះទេ តែសូម លើកទឹកចិត្តឱ្យពិចារណារលើបទពិសោធន៍ជោគជ័យនៅក្នុងលទ្ធផលទាំងបី និងការសន្ទត់ផ្សេងៗ រួមទាំងវិធានការទាំង៦ របស់ OECD-DAC ដែលត្រូវយកមកប្រើប្រាស់ជាមូលដ្ឋានដើម្បីអនុវត្តបន្ត នៅក្នុងជំហានក្រោយៗទៀត។**

## សម្រាប់ការរៀបចំកម្មវិធីឬគម្រោងនាពេលអនាគត៖

១. គម្រូក្នុងការគាំទ្រនិងលើកកម្ពស់ស្ត្រីជាអ្នកដឹកនាំនៅក្នុងគម្រោង IP2 គួរត្រូវបានចងក្រងជាឯកសារជាក់លាក់ និងចែករំលែកឱ្យបានទូលំទូលាយទៅកាន់បណ្តាប្រទេសផ្សេងទៀត ដើម្បីយកតម្រាប់តាម និងអនុវត្ត បន្ថែមពីប្រទេសដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន រួមទាំងក្នុងគម្រោង ឬកម្មវិធីផ្សេងទៀតផងដែរ។ ចំណុចល្អនេះ ជាផ្នែកសំខាន់ដែលនឹង ត្រូវដាក់បញ្ចូលទៅក្នុងគម្រោង បរិយាប័ន្នទឹកនាពេលអនាគត។

២. ត្រូវក្តាប់ឱ្យបាននរឿងរ៉ាវនៃការផ្លាស់ប្តូររបស់ស្ត្រីម្នាក់ៗ ពោលគឺនិយាមប្រតិបត្តិផ្នែកយេនឌ័រទាំងស្រុង និងវិធីនៃការផ្លាស់ប្តូរ តាមការរៀបរាប់របស់ពួកគេ សម្រាប់ការងារពាក់ព័ន្ធ ទៅនឹងស្ត្រីជាអ្នកដឹកនាំនាពេលអនាគត។

៣. សម្រាប់គម្រោងជំហានបន្ទាប់ ត្រូវផ្តោតការយកចិត្តទុកដាក់លើការជំរុញតួនាទីរបស់ស្ត្រី ជាអ្នកដឹកនាំពីសហគមន៍ទៅក្នុង យន្តការថ្នាក់ជាតិ និងថ្នាក់តំបន់ ដោយដកស្រង់ និងច្របាច់បញ្ចូលពីការអនុវត្តនិងមេរៀនជោគជ័យរបស់គម្រោង IP2 ។

៤. យុទ្ធសាស្ត្រប្រទាក់ក្រឡានិងភាពច្បាស់លាស់ ផ្អែកតាមបទពិសោធន៍សម្បូរបែបរបស់ គម្រោង IP2 ក្នុងការដាក់បញ្ចូលជនមានពិការភាព ក្រុមស្រឡាញ់ភេទដូចគ្នាឬនិន្នាការ ភេទចម្រុះ (SOGIE) ចាំបាច់ត្រូវរៀបចំសម្រាប់គម្រោងបរិយាប័ន្នទឹកជំហានបន្ទាប់។ អង្គការតំណាងជនមានពិការភាព (OPDs) និងស្ថាប័ន SOGIE ត្រូវចូលរួមរៀបចំគម្រោង នាពេលអនាគតដោយផ្ទាល់។

៥. ចងក្រងមេរៀនជោគជ័យ ដែលបានអនុវត្តនៅក្នុងគម្រោង IP2 អំពីការលើកស្ទួយស្ត្រី ជនជាតិដើមភាគតិចជាអ្នកដឹកនាំ ដោយត្រូវផ្សព្វផ្សាយឱ្យបាននៅទូទាំងតំបន់មេគង្គ និងគាំទ្របន្ថែមក្នុងការផ្សារភ្ជាប់ទំនាក់ទំនងជាមួយបណ្តាញស្ត្រីនិយម ដែលជាជនជាតិ ដើមភាគតិចនៅទូទាំងពិភពលោក ។

៦. មេរៀនដកស្រង់ស្តីពីការចូលរួមរបស់យុវជន នៅក្នុងគ្រប់សមាសធាតុរបស់គម្រោង IP2 ត្រូវចងក្រងដោយរំលេចពីយុទ្ធសាស្ត្រផ្តោតលើយុវជន ដើម្បីយកទៅអនុវត្តក្នុងកម្មវិធី ក្រោយជាបន្តទៀត។

៧. ស្វែងរកធនធានដើម្បីបន្តគាំទ្រដល់សហគមន៍នេសាទ បណ្តាញនិងសហគមន៍មូលដ្ឋាន ពីប្រភព ផ្សេងទៀតដែលឯករាជ្យពីម្ចាស់ជំនួយស្ថាប័ន ផ្តោតអាទិភាពលើការតស៊ូមតិ ដើម្បីទទួលបាន ថវិកាគាំទ្រពីអង្គភាពជំនាញរបស់រដ្ឋាភិបាលក្នុងស្រុក។

៨. ផ្តោតការយកចិត្តទុកដាក់លើទម្រង់នៃភាពជាដៃគូ ការវិវត្តនិងវឌ្ឍនភាព អំឡុងពេល អនុវត្ត គម្រោង ជាពិសេសភាពរឹងមាំរបស់អង្គការសហគមន៍ពីមួយទៅមួយដំណាក់កាល ដែលអាច ពង្រឹងជំហរបានដោយខ្លួនឯង ពុំសូវពឹងអាស្រ័យលើអន្តរាគមន៍ពីដៃគូអង្គការ សង្គមស៊ីវិល។

៩. ក្នុងការបង្កើតទ្រឹស្តីនៃការផ្លាស់ប្តូរសម្រាប់ជំហានបន្ទាប់របស់គម្រោងបរិយាប័ន្នទឹក ត្រូវ ពិចារណា ឱ្យបានជិតដល់លើបរិបទសង្គមនិងសេដ្ឋកិច្ច និងលំហសង្គមស៊ីវិលនៅក្នុង ប្រទេសនីមួយៗ ក៏ដូចជាត្រូវឆ្លុះបញ្ចាំងនៅក្នុងទ្រឹស្តីនៃសកម្មភាព។

១០. ក្នុងការរៀបចំគម្រោងបរិយាប័ន្នទឹកជំហានបន្ទាប់ ត្រូវបញ្ជាក់ឱ្យបានច្បាស់ពីទិដ្ឋភាព អំណោយ ផលនិងកត្តាជោគជ័យក្នុងការលើកស្ទួយថ្នាក់ដឹកនាំក្នុងមូលដ្ឋាន ការផ្សាភ្ជាប់ ទៅនឹងយន្តការថ្នាក់ ជាតិ និងថ្នាក់តំបន់ ប្រកបដោយឥទ្ធិពលនិងភាពប្រទាក់ក្រឡា ដោយ ត្រូវពិចារណាលើស្ថានភាព ជាក់ស្តែងរបស់ប្រទេសនីមួយៗ និងឧបសគ្គដូចបានលើក ឡើងក្នុងអនុសាសន៍ទី៤។

១១. បង្កើតយុទ្ធសាស្ត្រលម្អិតសម្រាប់គម្រោងបន្ទាប់ ក្នុងការលើកកម្ពស់និងគាំទ្រដល់ គំនិតផ្តួចផ្តើម ស្តីពីថាមពលកកើតឡើងវិញ ផ្តើមចេញពីថ្នាក់មូលដ្ឋានទៅថ្នាក់តំបន់ ដោយ ក្នុងនោះត្រូវស្វែងរក លទ្ធភាពសហការជាមួយគំនិតផ្តួចផ្តើមផ្សេងទៀតរបស់ DFAT នៅ ក្នុងតំបន់។

១២. កត់ត្រាមេរៀនដកស្រង់ស្តីពីកិច្ចសហការនិងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ “តាមបែប ប្រពៃណី” និងបណ្តាញសង្គមនៅទូទាំងតំបន់ក្នុងអំឡុងពេលអនុវត្ត IP2 និងធ្វើការវិភាគ ដើម្បីតាក់តែង យុទ្ធសាស្ត្រតាមសមាសភាគសម្រាប់អន្តរាគមន៍នាពេលអនាគត។ ការងារ ទំនាក់ទំនងនិង ផ្សព្វផ្សាយនាអនាគត ត្រូវដាក់បញ្ចូលការចែករំលែករឿងរ៉ាវជោគជ័យ និងទិន្នន័យ ដែលបង្ហាញ ពីសារៈសំខាន់នៃការគិតគូរអំពីយេនឌ័រ និងការចូលរួមរបស់ សហគមន៍ទៅក្នុងគោលនយោបាយ ។

១៣. កត់ត្រាមេរៀនដកស្រង់ស្តីពីកិច្ចសហការជាមួយគ្រឹះស្ថានសិក្សាស្រាវជ្រាវ ដែលជា យន្តការទ្វេទិស ពោលគឺ ទី១ ជាច្រកឬមុខព្រួយនៃការបង្កើតផលជះដោយផ្ទាល់ និងទី២ ភស្តុតាងបញ្ជាក់ពី ការបង្កើតឥទ្ធិពល តាមរយៈភាពជាដៃគូដើម្បីអភិវឌ្ឍន៍និងផ្តល់ភាព អង់អាចដល់សហគមន៍។ វិធានការជាក់លាក់ ដែលត្រូវអនុវត្តរួមមាន ៖

- **ពង្រឹងកិច្ចសហប្រតិបត្តិលើការស្រាវជ្រាវ៖ ជំរុញភាពជាដៃគូរវាងសាកលវិទ្យាល័យ ក្នុង ស្រុក និងស្ថាប័នស្រាវជ្រាវអន្តរជាតិ ដើម្បីបង្កើតទិន្នន័យពាក់ព័ន្ធ និងការសិក្សា ផ្អែកលើ ភស្តុតាងដែលរួមចំណែកដោះស្រាយបញ្ហាសហគមន៍ និងយេនឌ័រ។**
- **កសាងសមត្ថភាពស្ថាប័នស្រាវជ្រាវក្នុងស្រុក៖** ផ្តល់ធនធាន និងបណ្តុះបណ្តាល អ្នកស្រាវជ្រាវក្នុងស្រុក ដែលមានជំនាញនិងទំនាក់ទំនង រួមទាំងចំណាប់ចំណូលចិត្ត សិក្សាអំពីយេនឌ័រ ការអភិវឌ្ឍសហគមន៍ និងការវិភាគគោលនយោបាយ ក្នុងគោលដៅ រួមចំណែកដល់កិច្ចពិភាក្សាប្រកបដោយប្រសិទ្ធភាព។
- **ការបោះពុម្ព** និងផ្សព្វផ្សាយ៖ បង្កើនការផ្សព្វផ្សាយ និងការយល់ដឹងឱ្យបានកាន់តែ ទូលំទូលាយ តាមរយៈការបោះពុម្ពផ្សាយរបកគំហើញនៅក្នុងទិនានុប្បវត្តិ និងប្រព័ន្ធ ផ្សព្វផ្សាយពេញនិយមនានា ដែលការរកឃើញនោះបម្រើ ដល់សាធារណជនទូទៅ រួមទាំងអ្នកតាក់តែងគោលនយោបាយ។

- កំណត់ពន្យល់ស្តីពីគោលនយោបាយនិងអនុសាសន៍៖ ផ្អែកតាមការរកឃើញ គាំទ្រដល់កិច្ចសហប្រតិបត្តិការ ក្នុងការបង្កើតកំណត់ពន្យល់ស្តីពីគោលនយោបាយផ្អែកលើមូលដ្ឋានភស្តុតាង និងភាពច្បាស់លាស់ ដើម្បីដាក់ចេញនូវអនុសាសន៍ដែលអាចអនុវត្តបានសម្រាប់អ្នកតាក់តែងគោលនយោបាយមានឥទ្ធិពល ឬអង្គភាពជំនាញ របស់រដ្ឋដែលស្វាគមន៍កិច្ចសន្ទនាដោយបើកចំហ។
- **ការចូលរួមកិច្ចសន្ទនាគោលនយោបាយ៖ ស្របតាមបរិបទនិងលំហផ្លូវការដែលមានរៀបចំវេទិកា** សិក្ខាសាលានិងកិច្ចពិភាក្សាតុមូល ប្រមូលផ្តុំដោយបញ្ញវ័ន្ត អ្នកស្រាវជ្រាវ អ្នកបង្កើតគោលនយោបាយ និងតំណាងសហគមន៍ ដើម្បីពិភាក្សាអំពីការរកឃើញ និងភាពពាក់ព័ន្ធទៅនឹងគោលនយោបាយ ។

១៤. ទាំងអង្គការអុកស្វាមនិងទន្លេអន្តរជាតិ គួររួមគ្នាពិនិត្យមើលឡើងវិញលើចំណុចជោគជ័យ និងឧបសគ្គ ក្នុងការជំរុញឱ្យមានការចូលរួមពីវិស័យឯកជនជាមួយគម្រោងបរិយាប័ន្នទឹក ទាំងពីរដំណាក់កាលរហូតមកដល់ពេលនេះ ដោយថ្លឹងថ្លែង និងគិតគូរពីយុទ្ធសាស្ត្រ បង្កលទ្ធភាពឱ្យក្រុមហ៊ុនអភិវឌ្ឍន៍វារីអគ្គិសនី ស្ថាប័នហិរញ្ញវត្ថុ តួអង្គពីវិស័យឯកជនផ្សេងៗ ថាមពលកកើតឡើងវិញ ចូលរួមដោយផ្ទាល់ ឬ ប្រយោល ក្នុងគោលដៅបង្កើតឥទ្ធិពល ជាវិជ្ជមានដោយប្រើប្រាស់ដៃគូអង្គការសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ អ្នកស្រាវជ្រាវ និង គ្រឹះស្ថានសិក្សាធិការ។

## បញ្ហាផ្នែកប្រតិបត្តិការ និងរចនាសម្ព័ន្ធ៖

១៥. បញ្ហាយល់ច្រឡំដែលនៅសេសសល់ ទាក់ទងនឹងការចូលរួម ការប្រាស្រ័យទាក់ទង ជាមួយម្ចាស់ជំនួយ  និងលក្ខខណ្ឌតម្រូវផ្នែកគណនេយ្យភាព ត្រូវចាត់អាទិភាព និង ដោះស្រាយ ដើម្បីបង្កើនប្រសិទ្ធភាពនៃភាពពាក់ព័ន្ធ និងការរួមចំណែករបស់ម្ចាស់ជំនួយ ទៅក្នុងគម្រោង និងបង្កើតឱ្យមានសុខដុមនីយកម្មផ្នែកគណនេយ្យភាព ដែលជាបញ្ហាយូរ លង់ណាស់មកហើយ។

១៦. សម្រាប់កម្មវិធីនានារបស់អង្គការអុកស្វាមនាពេលអនាគត ត្រូវញែកគ្នាឱ្យដាច់រវាង រចនាសម្ព័ន្ធគ្រប់គ្រងគម្រោងថ្នាក់តំបន់ និងស្វ័យភាពរបស់ក្រុមការងារអង្គការអុកស្វាម ប្រចាំប្រទេសនីមួយៗ។

១៧. អង្គការ Oxfam គួរតែពិភាក្សាផ្ទៃក្នុងនិងជាមួយម្ចាស់ជំនួយ អំពីការគ្រប់គ្រងលើ លំហូរប្រតិបត្តិការបច្ចុប្បន្ន បន្ទុកការងារ និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ (បុគ្គលិក ក្នុងតួនាទីដឹកនាំ) ដើម្បីសម្របសម្រួលឱ្យមានលំហូរបែងចែក និងការចូលរួមនៅក្នុង កម្មវិធីប្រកបដោយគុណភាព និងជាយុទ្ធសាស្ត្រ។

១៨. អត្ថប្រយោជន៍ដែលទទួលបានពីអន្តរកម្ម និងការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ក្នុងការអនុវត្តគម្រោង IP2 រវាង IR និង Oxfam លើការងារអភិបាលកិច្ចទឹក (WRG), ថាមពលកកើតឡើងវិញ (RE) និងការគ្រប់គ្រងធនធានធម្មជាតិ (NRM) ត្រូវទទួល ស្គាល់និងយកទៅប្រើប្រាស់បន្តក្នុងកម្មវិធីផ្សេងៗទៀត ក៏ដូចជាពង្រីកបន្ថែមដើម្បីឱ្យមាន អន្តរកម្មជាប្រព័ន្ធជាមួយបណ្តាគម្រោងដែលគាំទ្រមូលនិធិដោយ SDC និង DFAT ។

**Oxfam in Cambodia**
The Point, 3F, No. 113C, Mao Tse Tung Blvd.,
Tuol Svay Prey I, Beung Keng Kang, Phnom Penh, Cambodia

(855) 23885 412 / (855) 23885413

Info.Cambodia@oxfam.org

asia.oxfam.org